# ការសម្ភាសរបស់ថៃ  ស៊ីម សុខងឹម

កះអ្នកសម្ភាសឈ្មោះ កុយ សុភី          ខះអ្នកត្រូវគេសម្ភាស ស៊ីម សុខងឹម

កះ ចាស!ខ្ញុំជំរាបសួរថៃ!

ខះ អឺជំរាបសួរអូន!

កះចាសថៃសព្វថ្ងៃថៃសុខសប្បាយជានាទេហ៎?

ខះ អឺសុខសប្បាយជាធម្មតានោះទេ។

កះ
ខ្ញុំឈ្មោះកុយសុភីមកជួបថៃគឺមានគោលបំណងសុំសម្ភាសប្រវត្តិផ្ទាល់ខ្លួនរបស់ថៃដែលមានការទំនាក់ទំនងទៅនិងក្រុមគ្រួសារនិមួយៗនៃប្រជាពលរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីរក្សាពង្សប្រវត្តិអោយចាស់ៗជំនាន់មុខទុកអោយក្មេងៗជំនាន់ក្រោយបានលឺបានដឹងសម្លេងរបស់ប្អូន។ តើប្អូនអនុញ្ញាតអោយបងធ្វើការសម្ភាសបានដែរឬទេ?

ខះ បានចេះចាំបានប៉ុន្មានឆ្លើយប៉ុណ្ណឹងហ៎។

កះ ចឹងថ្ងៃនេះគឺជាថ្ងៃពុធ ខែសីហានៅក្នុងឆ្នាំ២០១៨នៅក្នុងភូមិពាមក្នុង
ឃុំព្រៃកក្របៅស្រុកកងមាស
ខេត្តកំពង់ចាម។ជាកិច្ចចាប់ផ្តើមមុនដំបូងខ្ញុំសូមស្គាល់ឈ្មោះថៃនៅក្នុងអត្តសញ្ញាណប័ណ្ណមានឈ្មោះអ្វី?

ខះ ឈ្មោះ ស៊ីម សុខងឹម។

កះ ចាសឈ្មោះហ្នឹងនរណាជាអ្នកដាក់អោយថៃ?

ខះ ម្តាយនិងឪពុកជាអ្នកដែលដាក់អោយថៃ។

កះ ចាសហើយចុះឈ្មោះហ្នឹងមានអត្តន័យយ៉ាងម៉េចដែរ?

ខះ ឈ្មោះហ្នឹងដែលគាត់ដាក់ថាសុខ ងឹមហ្នឹងប្រហែលជាគាត់ចង់អោយមានសេចក្តីសុខ។

កះ អូ

ខ៖ អោយវាមានសុខ គឺឈ្មោះហ្នឹងដាក់ទៅអោយវាមានសេចក្ដីសុខ។

ក៖ ចៃមានឈ្មោះហៅក្រៅមួយទៀតដែស?

ខ៖ អត់នោះទេមានតែឈ្មោះហ្នឹងតែមួយ។

ក៖ ចៃទីកន្លែងដែលបានកើតនៅភូមិអី?

ខ៖ កើតនៅក្នុងភូមិពាមក្នុងហ្នឹងតែម្ដង។

ក៖ ឃុំ?

ខ៖ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាមយើងហ្នឹង។

ក៖ ចាស!ឈ្មោះពេញរបស់ឪពុកចៃគាត់មានឈ្មោះអ្វី?

ខ៖ ឈ្មោះឪពុកហ៎គាត់មានឈ្មោះថា សយ ស៊ឹម។

ក៖ គាត់មានដែលដំណាលប្រាប់ថាឈ្មោះគាត់មានអត្ថន័យយ៉ាងម៉េចដែរ?

ខ៖ ទេមិនដឹងជាប្រវត្តិអត្ថន័យរបស់គាត់ដែលនុងទេព្រោះអីនៅតូចៗ
ពេលកើតដឹងក្ដីឡើងលឺតែគាត់និយាយថាចឹង
ហើយបានឃើញនៅក្នុងបញ្ជីជាតិអីគឺគាត់ឈ្មោះ សយ ស៊ឹម។

ក៖ អឺឈ្មោះហ្នឹងនរណាបានដាក់ឈ្មោះអោយដល់គាត់ដែរគាត់មានបានប្រាប់ដែរឬទេ?

ខ៖
មើលឈ្មោះហ្នឹងគាត់មិនបានជារៀបរាប់នោះទេប្រហែលជាឪពុកម្ដាយរបស់គាត់ជាអ្នកដែល
ដាក់ឈ្មោះអោយដែលហើយ។ ឪពុកម្ដាយតាសយនុងគាត់ជាអ្នកដាក់អោយដែលនុង។

ក៖ ចាសហើយគាត់មានឈ្មោះហៅក្រៅទៀតដែស?

ខ៖ អត់នោះទេគាត់មានឈ្មោះតែមួយហ្នឹងគេហៅគាត់តែចឹង។

ក៖ ចាស

ខ៖ គេហៅថាអ៊ុំ ស៊ឹមទៅ ចឹកស៊ឹមទៅគ្រាប់តែគ្នាក្មួយៗរបស់គាត់ គាត់បានហៅចឹង។

កៈ គាត់នៅរស់នៅតើគាត់សព្វថ្ងៃនេះហ្នឹងគាត់នៅរស់នៅឬទេ?

ខៈ គាត់ស្លាប់ទៅហើយ។

កៈ គាត់ស្លាប់នៅពេលអាយុគាត់បានប៉ុន្មានដែរបានជាគាត់ស្លាប់នុង?

ខៈ នៅពេលគាត់បានអាយុ៥៩។

កៈ៥៩ កាលនុងគាត់បានស្លាប់ដោយសារមូលហេតុអ្វី?

ខៈ គាត់ស្លាប់ដោយសារតែជំងឺ។

កៈ ចឹងគាត់ស្លាប់ដោយសារតែជំងឺព្យាពាធទេហ៎?

ខៈ នុងហើយជំងឺព្យាពាធធម្មតារបស់គាត់។

កៈ ចាស!ចុះចៃចាំទេកាលនុងគាត់កើតជំងឺអ្វីគេ?

ខៈ និយាយទៅកាលនុងវាវែងឆ្ងាយដែរនុង!និយាយថាឈឺទៅ!ជំងឺនុងថាទឹកចូលក្នុងសួត។

កៈ អូ!

ខៈ
ដំបូងថាឈឺចុកចាប់នៅក្នុងប្រាណហ្នឹងហើយក៏រកខាងអពៃជំនឿននុងវាចេះតែឃើញហើយ។

កៈ ចាស!

ខៈ ថាត្រូវនេះត្រូវនោះមានអំពើអីចឹងទៅ។

កៈ កាលនុងមានពេទ្យគេមើលអីដែលមានលក្ខណៈមួយរាងទូលំទូលាយដែស?

ខៈ មានពេទ្យហើយ។

កៈ មានពេទ្យដែរហ៎!

ខៈ
មានមុខដំបូងគឺយើងរកគ្រូខ្មែរដល់គ្រូខ្មែរសិនបើថាមិនជាទើបយកទៅដេកនៅឯគ្រូពេទ្យនៅកំពង់ចាម។

កៈ យកទៅ!

ខៈ អើយកទៅដេកពេទ្យឯនុងដល់ទៅ៦ខែ!

កៈ អូ

ខៈ តែវាមិនបានបាត់នោះទេដល់ពេលយកមកដល់ផ្ទះបាន៦ខែក៏គាត់បានខូចទៅ។

កៈ ចាស!

ខៈ ថាជំងឺយើងវាខកហើយណា។

កៈ ចាសចឹងគាត់ណា ទីកន្លែងដែលតាបានកើតនៅឯណាដែរចៃ?

ខៈ នៅឯភូមិពាមក្នុងហ្នឹងដែរ។

កៈ អូ!ចឹងស្រុកកំណើតរបស់គាត់ហ្នឹងគឺជាអ្នកកំណើតខាងម្ដាយរបស់គាត់ឬក៏ខាងឪពុក?

ខៈ ស្រុកកំណើតហ្នឹងគឺខាងម្ដាយគឺយាយ អៀកហ្នឹង។

កៈ ចុះកាលនុងគាត់មានបានរៀនដល់ថ្នាក់ត្រឹមទីប៉ុន្មានដែរ?

ខៈ
គាត់ប្រហែលជាមិនបានរៀនបានចូលសាលានោះទេព្រោះអីបានលឺគាត់ថាប្រវត្តិរបស់គាត់កំសត់ដែលបានរៀននៅឯក្នុងវត្ត។

កៈ រៀននៅក្នុងវត្ត?

ខៈ អើរៀននៅវត្ត។

កៈ បើសិនជាបានរៀននៅឯវត្តចេះអក្សរបាលីអីដែរចឹង?

ខៈ ចេះដែរតើហ្នឹងហើយ។

កៈ ចុះគាត់មានបានប្រាប់ថាគាត់ចេះក្បាច់គេដែលបានគិតលេខនោះចេះដែស?

ខៈ ទេអាក្បាច់គ្រាប់ៗនុង ហេស!!អាក្បាច់គិតលេខនោះគាត់ចេះណាចាស!

កៈ ឥឡូវនេះហ្នឹងយើងគិតលេខអីភាគច្រើនគឺគិតកាសស្ស(ម៉ាស៊ីនគិតលេខ)

ខ៖ ចាស

ក៖
តែកាលពីសម័យកាលពីដើមនុងមានកាសស្សូនោះទេចឹងមានតែការគិតនុងគឺលក់ដូរអីគិតចឹងហំណាស់!

ខ៖ នុងផ្ទះថៃនៅមានក្បាច់នុងមួយដែរ។

ក៖ នុងបានក្បាច់នុងវាចង់គិតលេខលឿនជាងកាសស្សូទៀតថៃ!
ម៉ា១គ្រាប់នុងគេ១លានអី១សែន។

ខ៖ កាលនុងមិនបានចេះអីនុងទេគ្រាន់តែបានឃើញគាត់គិតចឹងដែរណា។

ក៖ ចាស!

ខ៖ ដឹងតែមានគាត់បានគិតក្បាច់នុង។

ក៖
ចាសចឹងគាត់ចេះគិតក្បាច់នុងដែរហើយចាស!ហើយទៅគាត់មានចេះភាសាអីក្រៅពីភាសាខ្មែរយើងដែរ?

ខ៖
យឺស!គាត់ដូចជាមិនចេះទេវៃដូចជាមិនដែលបានលឺនិយាយអីនោះទេព្រោះអីកាលនុងគាត់បានរៀននៅឯក្នុងវត្ត។

ក៖ ចុះភាសាចិនអីគាត់ចេះដែស?

ខ៖ ចិនអីគាត់គ្រាន់តែប្រាប់ថា គ្រាន់តែថាជៀកពឹងអីហ្នឹងចឹងទៅ។

ក៖ គាត់ចេះនិយាយហើយអត់ចេះសរសេរអក្សរអីដែស?

ខ៖ អក្សរក៏អត់មិនចេះដែរ។

ក៖ អក្សរចិននុង?

ខ៖ មិនចេះអីនោះទេគ្រាន់តែគាត់បានប្រាប់ថាចិកជៀកពឹកភាសាចិនគេថាញាំបាយ
ស៊ីបាយណាកូន ចាងអ៊ែកពាក្យមុជទឹកចឹងទៅ។

ក៖ ចឹងគាត់កាន់សាសនាអ្វី?

ខ៖ គាត់កាន់សាសនាព្រះពុទ្ធ។

ក៖ ចាស! អត្តចរិតរបស់លោកតាមិចដែរ?

ខ៖
អត្តចរិតរបស់តាហ្នឹងគឺស្លូតណាស់។អ្នកស្រុកគេនិយាយតែម្តងថាមិនមែនតែគាត់ជាឪពុកចៃបានចៃដឹងថាគាត់ហ្នឹងស្លូតនោះទេ
អ្នកស្រុកក៏គេបានសរសើរថាគាត់ហ្នឹងបានស្លូតដូចគ្នាហើយគាត់អត់ចេះនិយាយច្រើនទេ។

ក៖ ចាស!ចុះមុខរបររបស់គាត់កាលនុងគាត់ធ្វើអ្វីគេដែរ?

ខ៖ គាត់ធ្វើស្រែធ្វើចំការអីហ្នឹងនៅខាងជើងផ្ទះហ្នឹងគាត់បានភ្ជួរដាំអីនៅឯខាងជើងផ្ទះហ្នឹង គាត់ធ្វើចំការប្រើតែនង្គលរនាស់មិនដែលមានគោយន្តបានភ្ជួរដូចនៅសម័យឥឡូវនេះនោះទេ។

ក៖ ចាសហើយចុះចំណែកអឺ!ម្តាយរបស់ចៃវិញឈ្មោះពេញរបស់គាត់មានឈ្មោះអ្វីដែរចៃ?

ខ៖ ឈ្មោះអឺ!ស៊ី សុខអឿនដែរ។ ម្តាយមានឈ្មោះថាយាយ អឿនៗហ្នឹង។

ក៖ ចឹងសព្វថ្ងៃគាត់នៅរស់ដែរឬទេ?

ខ៖ គាត់ស្លាប់ហើយគាត់បានស្លាប់ទៅមុនឪពុករបស់គាត់នោះទៅទៀតហ៎។

ក៖ អូ!

ខ៖ គាត់ប្រហែលជាអាយុជាងហា
គាត់ស្លាប់នុងដូចថាគាត់បានគ្រុំគ្រាពីកាលនៅជំនាន់អាពតមកណា។

ក៖ ចាស!

ខ៖
ចេះតែឈឺស្រកហើមៗមកពេលដែលបានដាច់ភ្លាមហ្នឹងដូចស្គុលដូចជាមិនសូវជាមានកំលាំងអីណា

រួចដល់ទៅហៅពេទ្យគេនុងមកចាក់ហើយពេទ្យនុងដូចថាជាពេទ្យដំបូងៗនុងពេទ្យនៅសល់ពីសង្គមមកយកមកចាក់គាត់បានប្រតិកម្មថ្នាំស្លាប់។

ក៖ ចឹងមូលហេតុរបស់គាត់គឺឈឺទៅចាក់ដោយសារហៅពេទ្យមកចាក់ទៅប្រតិកម្ម?

ខ៖ កាលដែលគាត់ឈឺនុងមិនទៅខ្លាំងនោះទេ។

ក៖ ចាស

ខ៖
ឈឺខ្ញុំនស្លាប់មួយចំហៀងខ្លួនប៉ុន្តែឈឺជាធម្មតានោះទេមិនចុកមិនចាប់អីនោះទេគ្រាន់តែថាដៃមួយចំហៀងហ្នឹងលើវាមិនរួចមែន
ដល់ទៅឃើញគាត់មិនសូវមានកំលាំងចឹងក៏យើងបានទៅហៅពេទ្យអោយមកចាក់នៅជំនាន់នុងពេទ្យរ៉ាយើងគាត់ទើបតែទៅរៀនបានថ្មីថ្មោងដោយសារគាត់ទៅរៀនបាត់ទៅក៏ខ្ញុំបានទៅហៅយាយរុនណោះមិនបានដឹងសល់ពីសម័យសង្គមណាអោយមកចាក់
ដកតែម្មុលទៅគាត់ស្លាប់តែម្តងហ្នឹង។

ក៖ គាត់មកពីសង្គមចាស់!

ខ៖ ពេទ្យនុងមិនដឹងជាពេទ្យស្អីគេទេកាលពីសង្គមចាស់នុងហ៎
ដកតែម្មុលរកខ្យល់ស្លាប់តែម្តងនុងហ៎ តែមួយភ្លែកភ្លាមនុងហ៎ ។

ក៖ គាត់បានរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ មិនបានដឹងទេគ្រាន់តែបានលឺអ្នកព្រែកក្របៅថាគាត់បានរៀនចូលសាលា
ថាចៃអឿនៗបានរៀននៅសាលាជាមួយខ្ញុំគាត់ស្លូតណាស់។

ក៖ ចាសចឹងគាត់បានចូលរៀន។

ខ៖ ចាស!ហ្នឹហើយគាត់ស្លូតហើយស្អាតទៀត។

ក៖
គាត់មានដែលនិយាយភាសាអីអោយចៃបានស្តាប់ដែសកាលនៅជំនាន់នុងដូចជាមានភាសាបារាំង?

ខ៖ គាត់ដូចជាមិនដែលនោះទេ
គាត់មិនដែលនោះទេពេលនុងគាត់គ្រាន់តែថាយកសៀវភៅមកបង្រៀនកូនដូចជាសៀវនៅកាលពីសម័យកុមារស្ថានពីដើមចឹងអីនុងកាលនុងគាត់បានយកមកបង្រៀនដល់យើងដូចជាកខអីចឹងបានស្គាល់សព្វស្រះអ ស្រះអាអីចឹង!

ក៖ ចាស

ខ៖
ចៃចេះអីបានបន្តិចបន្តួចដោយសារតែមានម្តាយនិងឪពុកគាត់បានបង្រៀនចៃនៅឯផ្ទះនឹងទេណា។

ក៖
ចាសចឹងគាត់បានជួយបង្រៀនដល់ចៃបានបន្ថែមទៀតហើយទៅកាលនុងគាត់មានប្រកបមុខរបអ្វីដែរ?

ខ៖ មុខរបរបស់គាត់នុងកាលនុងគាត់បានធ្វើស្រែដែលនុង
ដល់ពេលខែធ្វើស្រែក៏គាត់ទៅធ្វើស្រែទៅដល់ខែដាំពោតក៏គាត់ទៅដាំពោតចឹងទៅកាលនុងមុខរបរបស់គាត់តែប៉ុណ្ណឹង។

ក៖ តើអត្តចរិតរបស់គាត់វិញយ៉ាងម៉េចដែរទៅចៃ?

ខ៖ អូចំពោះយាយនុងវិញកាន់តែស្លូតទៀតហើយលោកយាយ អឿននុងហ៎។

ក៖ ចាសចឹងទីកន្លែងដែលគាត់បានកើតនៅឯណាដែរ?

ខ៖
កន្លែងកំណើតហ្នឹងមិនបានដឹងនៅឯណានោះទេដឹងត្រឹមតែថាពេលដែលបានកើតដឹងក្តីមកឃើញគាត់រស់នៅក្នុងភូមិពាមក្នុងហ្នឹងតែម្តង។

ក៖
ចាស១!ហើយគាត់មានដែលនិយាយអំពីជីវៈប្រវត្តិរបស់គាត់តាំងពីដើមមកគាត់ដូចថាយ៉ាងម៉េចដែរប្រាប់ចៃ? គាត់មានដែរប្រាប់ដែរឬទេ?

ខ៖
គាត់បាននិយាយប្រាប់២នាក់ប្តីនិងប្រពន្ធនុងថាកាលពីជំនាន់មុននុងមានជំនាន់ឥសិរៈអីណា

ទៀតណ៎ព្រោះអីកាលនុងអត់បានដឹងផងព្រោះអីកាលនុងយើងបានជិះកង់ឈើហើយវាកំសត់វេទនាទៅគួតអីអត់មានដែកកេសប្រើទៅគួតឬស្សីអីចឹងណា
ថាកំសត់អស់កាលជំនាន់ពីដើមមកណា។

ក៖
ចឹងមានន័យថាកាលនុងគាត់កើតអត់ទាន់នោះទេក៏ប៉ុន្តែគាត់បានដឹងអំពីឪពុករបស់គាត់ទៀត!

ខ៖ ចាស!បែបជាចឹងហ្នឹងហើយ!

ក៖ ដែលបានដំណាល់ប្រាប់គាត់តណាចៃ?

ខ៖ ចាសហើសហ្នឹងហើយ!

ក៖
ចែកកាលនៅជំនាន់នុងខ្ញុំបានដឹងតាមរយៈម្ដាយឪពុករបស់ខ្ញុំគាត់បាននិយាយប្រាប់ដល់ខ្ញុំដែរគឺប្រើអំពង់ឬស្សីជាមួយនឹងអី...

ខ៖ ឈើក អំបែងចាននិង...

ក៖ សំឡីគ
ញាត់នៅក្នុងបំពង់ចឹងទៅហើយគេយកអំបែងចានមកផ្គុំជាមួយអំបែងដបយកមកទង្គិចអោយវាចេញជាព្រាយភ្លើងទៅឆេះសំឡីហ្នឹង។

ខ៖ ហ្នឹងហើយកូសវាអោយខ្លាំងដើម្បីអោយវាចេញព្រាយភ្លើងហើយឆេះសំឡីហ្នឹង។

ក៖
នុងហើយកាលហ្នឹងនៅក្នុងជំនាន់ឥសិរៈនុងហើយវាមិនទាន់មានអីសំបូរបែបដូចជាពេលឥឡូវណា។

ខ៖ហើស!

ក៖ ហ្នឹងនៅជំនាន់ឥសិរៈ!

ខ៖
អត់នោះទេពេលមកដល់ជំនាន់ឥសិរៈនុងចៃក៏មិនបានដឹងដែរថាកាលនៅឯជំនាន់ប៉ានុងអាស

ម័យសង្គ្រាមប៉ាហ្នឹងគាត់អត់មានដែកកេសចឹងគាត់បានប្រឆេះអំពង់នុងដែរ ព្រោះអីទៅទិញនៅឯណាបើសិនជាជំនាន់ទំលាក់គ្រាប់បែបនុង?

ក៖ មានតែថ្មអត់មានដែកកេស!

ខ៖ វាអត់មានដែកកេស!

ក៖ អូ

ខ៖ មួយរយៈនុងវាមានយន្តហោះវាបានមកទំលាក់ពេលសង្គ្រាមនោះហ្នឹង ចែនៅតូចៗប្រហែលបានអាយុបាន៧ទៅ៨ឆ្នាំ។

ក៖
ចែនិយាយចឹងខ្ញុំបាននឹកឃើញទៀតហើយពេលនុងតាធេងដែលនៅជិតដីរបស់ខ្ញុំនុង!គាត់មិនចាស់!

ខ៖ ហ្នឹង!

ក៖ លោកតាធេងនុងពេលទៅចូលទៅទិញអំពៅគាត់ហើយឃើញគាត់ពិសារបារី គាត់គូសអាបុសហ្នឹងដែរ។

ខ៖ ហ្នឹងគាត់បាននៅប្រើអាហ្នឹងនៅឡើយនោះទេ។

ក៖ អូ

ខ៖ រួចពីបានដាច់ជំនាន់ពពតនុងទៀតណា ប៉ាហ្នឹងគាត់ក៏ប្រឆេះបុសហ្នឹងដែរណា។

ក៖ ចាស

ខ៖ អត់មានដែកកេសនោះទេកាលនុងគាត់កំសត់ណាស់ណា។

ក៖ ចាសអឺស!

ខ៖ គេប្រើកាលនុងកំសត់ណាស់ហើយបានចូលទៅលួចពោតរបស់គេ ញ៉តចង្កោះខោនុងដោយយកមកស៊ីនៅ
ស៊ីអីជំនាន់ពពតចែកំសត់ណាស់លួចបានពោតអី១យកដាក់នៅក្នុងចង្កោះសំពត១មកកាលនុងវាភ័យញ័រអស់ហើយមិនបានទៅរកភ្លើងអីដុតនោះទេយកមកស៊ីទាំងនៅទៀតណំា។

ក៖ ចុះអត់ហើមពោះអីទេ?

ខ៖
អឺ!វាហើមហើយវាពគហើយប៉ុន្តែវាចេះតែស៊ីទៅបើសិនជាវាបាននុងឃ្លានហើយមានចេកផ្លែ
ហើយដល់ពេលចាស់ហើយទុំមិនហ៊ានកាប់ស៊ីនោះទេដល់ពេលចាស់ត្រូវបានស៊ីបាត់១ស្នូង
គេសម្លាប់។

ក៖ កម្មសិទ្ធិរបស់យើងសោះ!

ខ៖ ហ្នឹងហើយ!អានេះមកនៅជំនាន់កាលពពតយើងនេះ។

ក៖
កាលនុងគេហៅរបបរួមស្អីក៏រួមដែរនៅជំនាន់នុងហ៎។អត់មានជារបស់កម្មសិទ្ធិពីណាអីពីណា
នោះទេ។

ខ៖
អឺសមានគេដើរកាប់ប្រមូលយកទៅបន្ទុមហើយទៅក៏កាប់ប្រមូល១ម្នាក់ៗទៅពេលម៉ោងបាយ
នោះ។

ក៖ ចាស

ខ៖ កំសត់ណាស់កាលនៅក្នុងសម័យពពតនោះ។

ក៖
ចុះយាយហ្នឹងតាកាលនុងគាត់មានបាននិយាយដំណាលប្រាប់អំពីការមានគ្រួសារនុងបានឃើ
ញយាយនៅកន្លែងណាឬក៏បានឃើញត្រូវចិត្តគ្នាហើយបាននិយាយគ្នាដែរឬទេ?

ខ៖ មិនដែលបាននិយាយផង!

ក៖ អត់ដែលបាននិយាយទេ ថាគាត់បានរៀបអាពាហ៍ពិពាហ៍!

ខ៖ អាហ្នឹងគាត់បាននិយាយដែលថាពេលដែលគាត់ការយាយហាក់នេះ
យាយហាក់តាច្រើងដែលបានតែងរាប់ចំធ្វើផ្កាអោយដល់គាត់។

ក៖ គាត់មានបានផាត់មុខ លាបម្សៅ ក្រែបអីមានដែស?

ខ៖ អឺ!ម្ញៀវអីវាមានដែលកាលនុងតែគ្រាន់ថាម៉ៀវវារាងគ្រាប់ៗ។

ក៖ ចាស

ខ៖ កាលនៅជំនាន់នុងនិងគេហៅម៉ៀវសៀម។

ក៖ ម្ញៀវសៀមនុងហើយរូបកូនក្រមុំនុសគ្រាប់វាក្រអូបណាស់។

ខ៖ វាមានទាំងគ្រាប់និងម្ញៀវកញ្ចប់ទៀត!

ក៖ អានុងវាក្រអូបណាស់!

ខ៖ វាក្រអូបទាំងអស់ទាំងគ្រាប់ទាំងកញ្ចប់កាលនៅជំនាន់គាត់។

ក៖ ហើយចុះកាលនុងមានខោអាវប៉ាក់និងហូអី មានដែរហើយហ៎?

ខ៖ វាមានហើយហូអីនុះតែវាមិនសូវមានច្រើនសំបូរសប្បាយដល់ឥឡូវនោះទេ។

ក៖
ចុះកាលនុងពេលដែលនៅក្នុងពិធីមង្គលការមានគេរៀបចំកម្មវិធីដូចជាអុកកេសអីដែលជាកម្មវិធីបង្កើតបរិយាកាសអោយសប្បាយៗរីករាយកំដរដល់ភ្ញៀវអីដែស?

ខ៖ មានប៉ុន្តែមិនមែនជាអុកកេសនោះទគឺស្គរដៃគេហៅរាំឡាំផន។

ក៖ អូ

ខ៖ គេហៅស្គរដៃ កូដទ្រទៅគេហៅរាំឡាំផន។

ក៖ គេហៅលេងភ្លេងខ្មែរ។

ខ៖ គេហៅលេងភ្លេងខ្មែរអើម!

ក៖ ដល់ពេលយប់ទៅប្រគុំភ្លេងខ្មែរយើងហ្នឹងហើយរាំទៅ?

ខ៖ ហ្នឹងអានឹងគេហៅថាឡាំផន គេហៅថារាំឡាំផនទៀតមានរាំវង់អីនុង។

ក៖ រាំបទអោយស្វាយចន្ទី!

ខ៖ ហ្នឹង!

កៈ នារីអ្វអើយ! បទដើមត្នោតអី?

ខៈ មិនដឹងអីទេអានុងជំនាន់ក្រោយនោះទេបទដើមត្នោតនោះហ៎ ។

កៈ ខ្ញុំបានលឺគេច្រៀនចឹង។

ខៈ កាលជំនាន់នុងមានបទអោយផ្កាល្ហុងៗ ដុះនៅក្នុងព្រឹក្សាអីនុងលឺតែចឹង។

កៈ អោយផ្កាក្រវ៉ាន់អីដែរនុងណា!

ខៈ ឯងវាបានកើតទាន់ដែលកាលនុងវានៅវាងតូចៗ
បានលឺគេការនៅឯព្រៃកអណ្តូងនុងបានលឺតែស្គរដៃនឹង។

កៈ ចាស

ខៈ ហើយគាត់ក៏បានប្រាប់ថាកាលការគាត់ក៏ចឹងដែរ។

កៈ ហើយមានពិធីហៃលជំនួនមានអីចឹងដែរទេថៃ?

ខៈ ហឹស!ប្រហែលជាមាន
ហែស!ប្រហែលជាគ្មានពិធីហែលជំនួនអីនោះទេកាលនុងមានតែស៊ីជំនួន។

កៈ ចឹង?

ខៈ អឺ!បើសិនជាពិធីកាត់សក់វាមានដូចតែគ្នាហ្នឹងកាត់ មានកាត់សក់ដែរ។

កៈ ហើយចុះមានពិធីបុកល័ក្តអីដែសថៃ?

ខៈ
មានបុកល័ក្តអីដែរកាលជំនាន់នុងមានពិធីបុកល័ក្តហើយមកដល់កាលការនៅជំនាន់ថៃនុងក៏
មានពិធីបុកល័ក្តហ្នឹងដែរនេក។

កៈ ចាសព្រោះមកដល់ពេលសម័យឥឡូវនេះដូចជាចង់បាត់កម្មពិធីបុកល័ក្តហ្នឹងហើយ។

ខៈ មកដល់ពេលឥឡូវនេះដូចជាវាចង់បាត់ពិធីបុកល័ក្តហ្នឹងទៅហាស
មកដល់ពេលការប្អូនឯងមី ខេនអត់មានបុកល័ក្តនោះទេហើយដល់ពេលការឯង
ឯងបានទារចាស់ៗអោយមានពិធីបុកល័ក្តចឹងក៏គាត់បានបុកល័ក្តអោយទៅ។

កៈ ចឹងតា ស៊ឹមគាត់មានកូនប៉ុន្មាននាក់ដែរ?

ខៈ
កូនគាត់វាចំនួនទាំងអស់វាមាន៩នាក់ដែរប៉ុន្តែបានស្លាប់នៅក្នុងជំនាន់ពពតនុងមីមួយដែលបានកើតមកក្រោយគេបានត្រឹមអាយុប៉ុន្មានខែនោះទេបានយកទៅដាក់នៅឯមណ្ឌលនោះនិយាយតែប៉ុណ្ណឹងបានហើយ។

កៈ ឥឡូវកូនទី១គាត់ទី១មានឈ្មោះអី?

ខៈ កូនគាត់ទី១គឺចែហ្នឹងហើយដែលបងគេបំផុត។

កៈ អូ

ខៈ ឈ្មោះ ស៊ឹម សុខងីមហ្នឹង។

កៈ ចាស!ដល់មកទី២?

ខៈ ដល់មកទី២ឈ្មោះ ស៊ឹម សុខខេន។

កៈ គាត់បានចូលរៀនដែសចែកូនហ្នឹង?

ខៈ គេបានចូលរៀនត្រឹមថ្នាក់ទី៥ដែរកូនហ្នឹង
ចំណែកឯចែវិញមិនបានចូលរៀននោះទេព្រោះអីជីវៈភាពមានការខ្វះខាត ។

កៈ អូ

ខៈ
ចែនៅរកស៊ីចិញ្ចឹមប្អូនព្រោះម្ដាយដែលខ្ញិនមិនទាន់បានស្លាប់ពេលនុងគាត់រកស៊ីអីមិនកើត។

កៈ ចែដូចថាពេលនុងមានតួនាទីជំនួសដៃជើងម្ដាយ។

ខៈ អើមជំនួសម្ដាយ!

កៈ ចាស!សុខចិត្តអោយប្អូនៗបានទៅរៀនចុះ។

ខ៖ ហ្នឹងនៅក្នុងចិត្តហ្នឹងគឺសុខចិត្តអោយប្អូនៗគេរៀនចុះ សុខចិត្តអោយប្អូនចេះចុះ ប៉ុន្តែចៃក៏បានទៅរៀនដែលប៉ុន្តែចៃបានចូលរៀនអក្ខរៈកម្មបំពេញវិជ្ជានោះរៀនបានបន្តិចបន្តួចជាមួយចាស់ៗនៅវ័យកណ្តាល។

ក៖ ចឹងចៃសព្វថ្ងៃបានអានអក្សរអីបានដាច់ដែស?

ខ៖ ហេស!អាចដាច់!

ក៖ ដាក់ដុបខ្លះទៅ!

ខ៖ អឺដាក់ដុបខ្លះចឹងទៅចាស!

ក៖ គុណចៃកលេងអីចៃចេះដែស?

ខ៖ និយាយរឿងលេងអីចៃអត់ចេះនោះទេ និយាយអោយដាច់ចឹងតែម្តងទៅណា។

ក៖ ចាស

ខ៖
ព្រោះអីពេលនុងចៃអត់បានចូលសាលាបានតែបូកលេខអីបន្តិចបន្តួចនោះហើយតែបើសិនជានៅអក្សរនោះវាអាចអានបានដាច់ខ្លះ។

ក៖ ចុះបងទី៣មានឈ្មោះអីដែរ?

ខ៖ ប្អូនទី៣មានឈ្មោះថា ស៊ឹម សុខឈេនហ្នឹង។

ក៖ ប្រុសហ៎?

ខ៖ ប្រុស

ក៖ ហើយមកដល់ឥឡូវមានអាយុប៉ុន្មានហើយ?

ខ៖
ហឺស!មកដល់ឥឡូវនេះហ្នឹងមិនបានដឹងថាគេអាយុប៉ុន្មាននោះទេប៉ុន្តែគ្រាន់តែដឹងថាគេកើតនៅឆ្នាំកោរណា។

ក ៖ ចឹង!

ខ៖ អឺម

ក៖ ចុះពេលដែលគាត់មានគ្រួសារហើយទៅគាត់ទៅនៅឯណាដែរ?

ខ៖ គាត់នៅឯឃុំព្រែកក្របៅយើងហ្នឹងដែរនុងណា។

ក៖ ចាសហើយគាត់មានកូនបានប៉ុន្មាននាក់ដែរហើយនុង?

ខ៖ គាត់មានកូន២នាក់។

ក៖ មានកូនបាន២នាក់ចាស! មកបន្ទាប់ទៀតកូនទី៥នុះ?

ខ៖ កូនទី៥មានឈ្មោះថា ស្រីទូចជាកូនពៅគេ។

ក៖ ចាស!គាត់ទៅនៅខាងណាដែរ?

ខ៖ គាត់មកដល់ពេលសព្វថ្ងៃនេះហ្នឹងគឺគាត់បានទៅរស់នៅឯភ្នំពេញ ព្រែកលាបយើងនេះ។

ក៖ អូបានទៅរស់នៅឯភ្នំពេញទីក្រុង។

ខ៖ អឺម

ក៖ គាត់មានបានចូលរៀនដែស?

ខ៖ គាត់បានចូលរៀនដែរ បានចូលរៀនបានត្រឹមថ្នាក់ទី៦នៅភូមិពាមជីកង។

ក៖ អូបានខ្ពស់ដែរបានចូលដល់សាលាកាលេសដែលចឹងហ!

ខ៖ អឺអាឈេងក៏វាបានរៀនត្រឹមថ្នាក់ទី៦ដែរប៉ុន្តែមី
ខេនវាបានត្រឹមថ្នាក់ទី៥នៅឯពោធិសាលាទេ។

ក៖ ចាស

ខ៖
ប៉ុន្តែប្អូន១ប្រុសនុងវាភ្លេចអក្សរអស់ទៅហើយគ្នាអាប់ប្រាជ្ញណាស់កាលរៀននៅឯថ្នាក់ទី៦នុង ប៉ុន្តែមកដល់ពេលឥឡូវនេះភ្លេចបើសិនជាសរសេរអីអាចសរសេរកើតដែរនុងគេអាចអានបានខ្លះប៉ុន្តែគ្រាន់តែវាអន់ប្រាជ្ញណា មិនសូវចាំភ្លេចចង់អស់ហើយ។

កៈ
ហើយចុះស្រីទូចវិញគេមានប្តីទៅនៅឯខាងភ្នំពេញនេះដែរឬទេបានគេបានទៅនៅឯភ្នំពេញ?

ខៈ
គេមានប្តីនៅឯខាងក្រូចឆ្មាឯណំហើយគេមានប្តីដែលទៅធ្វើការភ្នំពេញហ្នឹងចឹងក៏បានទៅនៅឯទីនុងទៅ។

កៈ ឥឡូវមុខរបរបស់២នាក់ប្តីនិងប្រពន្ធនុងគេបានធ្វើអ្វីដែរ?

ខៈ មុខរបនុងមិនដឹងនោះទេ បើឡានអោយថៅវាយអ្នកដែលគេធ្វើការដែលនុងណា។

កៈ ចាស!ហើយចុះចំណែកឯខាងប្រពន្ធវិញបានធ្វើអ្វីដែរ?

ខៈ ប្រពន្ធនុងមើលកូននៅឯខាងផ្ទះ។

កៈ អូជាមេផ្ទះ។

ខៈ ឥឡូវបានកូន២នាក់ទៅហើយទៅឯណាមិនរួចនោះទេ!នៅថែរក្សាកូន។

កៈ ចាស!នៅថែរក្សាកូន។

ខៈ មើលកូននុង ជាមេផ្ទះនៅឯនុង។

កៈ
មេផ្ទះចឹងទៅចាស!ហឹស!ចុះកាលពីឪពុកម្តាយគាត់បាននៅរស់នៅគាត់បានរៀបចំបានកូនចំនួនបានប៉ុន្មានដែរ?

ខៈ គាត់រៀបបានអឺ ចែហ្នឹង មីខេន ឈេងហ្នឹងបាន៣នាក់ហ្នឹង។

កៈ បាន៣នាក់!

ខៈ និយាយទៅថាបាន៣នាក់ចឹងទាំងអស់ចឹងតែម្តងទៅណោស?

កៈ ចាសៗ!

ខៈ គាត់នៅនុះបានរៀបការកូនបានទាំងអស់។

កៈ ចាស!

ខ៖ រៀននៅឯកូននៅឯខាងភ្នំពេញនុង។

ក៖ ចាស
រៀបបានរៀបចំកូនចៅបានទាំងអស់អីបានរួចរាល់អស់ការហ្នឹងទៅតាមប្រពៃណីហើយ។

ខ៖ អឺម!

ក៖
ខ្ញុំសូមសួរបកក្រោយមកបន្តិចចៃពេលដែលបានរៀបការនុងសម័យនុងដូចថាបានសំបូរសប្បាយអីដូចជាឥឡូវនេះដែស?

ខ៖ សំរាប់ចៃហ៎?

ក៖ ចាស!

ខ៖ ហេស!ដូចជាមានសំបូរសប្បាយហ្នឹងគេដែរនុងកាលសម័យហ្នឹង។

ក៖ កាលនុងបានចាំដែស?

ខ៖ មិនបានដឹងថាកាលនុងក្នុង១គុប៉ុន្មានម៉ឺននោះទេនែក?
ដូចជា២០ម៉ឺនមិនដឹងឬក៏ជា៨ម៉ឺនមិនដឹងទេនេសអូសនៅរយនោះទេ
កាលនុងលុយនៅថ្លៃកាលការចៃជំនាន់ចៃនុង។

ក៖
ពេលដែលចៃបានរៀបអាពាហ៍ពិពាហ៍នុងកាលនុងចាស់ទុំគាត់ជាអ្នកដែលបានរៀបអោយឬក៏បានឃើញគ្នា ត្រូវចិត្តគ្នាហើយបានរៀបការ។

ខ៖មិនដែលបានឃើញគ្នាទាល់តែសោះកាលនុងភ័យរកតែម្តាយហើយនែកពេលគេមកដណ្តឹងហ្នឹង។

ក៖ អូ!ចឹងទៅតាមចាស់ទុំទេ?

ខ៖ តាមចាស់ទុំមានចាស់ម្នាក់នុងមានឈ្មោះ តាផន១
ដែលបានមកពីខាងស្រុករបស់គាត់នុងបានមកពីខាងព្រៃឈរមកអាឈើ
មកអាឈើអោយគេនោះទេមិនមែនអាអោយចៃនោះទេ។

ក៖ ចឹង

ខ៖ មកអានៅឯខាងផ្ទះញរណៃផេននេះហើយបានឃើញថៃ
ហើយបានទៅអួតប្រាប់ញាតិសណ្ដានរបស់គេថានៅឯខាងស្រុកនុងណាអំពីថៃ
ថាបានឃើញថៃមានអត្តចរិតអីល្អ
រូបរាងក៏បានសមរម្យទៅអួតប្រាប់ទៅបានគេនាំគ្នាមកស៊ើបសួរទំរាំតែបានថៃនោះនុងវា...

ក៖ បានគេចូលមកដណ្ដឹងទៅ!

ខ៖ អូស!កាលពីមកនុងមកស៊ើបសួរនុងញយដងណាទំរាំនុង។

ក៖ ប៉ុន្មានដង?

ខ៖ យូរណាស់ប្រហែល៣ទៅ៤ដងហ៎។

ក៖ ចាស!ចឹងមិនមែនមកតាម...

ខ៖ អត់ដែលបានស្គាល់គ្នានោះទេ!

ក៖
តាមចែកដូចថាមានបងប្អូនខ្សែរយៈខាងម្ដាយថៃឬក៏បងប្អូនខាងឪពុកកូនក្មួយខាងឪពុកឬក៏កូនក្មួយខាងម្ដាយអីចឹងណា!

ខ៖ មិនមែននោះទេតាមខ្សែរយៈអីចឹងនោះទេ។

ក៖ ព្រោះឃើញចាស់ៗកាលពីសម័យជំនាន់ដើមឃើញថាចឹង។

ខ៖ តែមានគាត់នោះមករកស៊ីខាងអាឈើហើយបានឃើញកូនក្រមុំគេចឹងរាងគ្រាន់បើណា។

ក៖ ចាស!

ខ៖ ចឹងគេក៏បានទៅបបរប្អូនគេមកដណ្ដឹងចឹង!

ក៖
ក៏អោយទៅឪពុកម្ដាយរបស់ថៃ?ហើយកាលនុងថៃអត់ដែរបានស្គាល់គេផងអត់មានប្រកែកអីនោះទេ?

ខ៖ មុនដំបូងនោះទៅស៊ើបសួរ។

ក៖ ឪពុកម្ដាយទៅស៊ើបសួរដែរ?

ខ៖
ម្ដាយរបស់ចៃបានទៅស៊ើបសួរបងប្អូននៅឯទួលចំបក់ឯនុងខ្លះដែរមានត្រូវជាជីដូនមួយម្ដាយឯងនុងហើយទៅសួរគេថាហ៉កអោយទៅទិតមឿនហ្នឹងគាត់បានធ្លាប់បួសហើយបានរៀនសូត្រអីចឹងណា។

ក៖ ចាស!ៗ

ខ៖
ក៏បានជឿទៅបានសំដីគេថាអ្នកហ្នឹងគេបានធ្លាប់ចេះបួសអីចឹងជាអ្នកដែលបានចេះដឹងហើយចឹងគាត់ក៏អោយ។

ក៖ អោយទៅតែចំណែកឯចិត្តរបស់ចៃណែក?

ខ៖ ចិត្តរបស់ចៃមិនសូវជាពេញចិត្តនោះទេព្រោះអីភ័យណាស់ព្រោះអីមិនដែរបានស្គាល់ខ្លាចណាស់។

ក៖ អត់ហ៊ានប្រកែកទេចឹង?

ខ៖ ប្រកែកដែរតែអ៊ី ស៊ាន់ គាត់ប្រាប់ថាហងនៅដល់ណាទៀត
អោយឪពុកចិញ្ចឹមដល់ណាទៀត?

ក៖ អូ

ខ៖ ហើយខ្ញុំក៏បានថាអ៊ី ស៊ាន់ឯងយកខ្លួនឯងទៅបើសិនជាចង់បាន!
ហើយទៅគាត់បានជេរខ្ញុំថាហេមីរយលហងក៏រឹងម៉េស?
មើលទៅឃើញថាគ្រាន់បើត្រឹមត្រូវម្ដាយឪពុកដាក់ហើយចេះប្រកែកប្រណាំងហងចាំរកគូខ្លួនឯងហែស?ហើយខ្ញុំក៏យំផងអីផងក៏លែងមាត់លែងកទៅណា។

ក៖ ចាស

ខ៖
ដល់ពេលអាថ្ងៃគេមកមើលថាភ្ជាប់ពាក្យភ្ជាប់សំដីនុងខ្ញុំភ័យចង់ងាប់ចង់រស់ឯនុសពេលហែល

ជំនួននុងទាល់តែចាប់ហើយដើរជាន់ជាយសំពត់ឡើងដួលហើយសួរទៅតានុងទៅវិញគេនិយាយសើចចង់ងាប់។

(សើច)

ការនៅជំនាន់នុងភ័យចង់ងាប់។

ក៖ ដល់ពេលថៃបានការហើយៗនិយាយថាបានរយៈពេលប៉ុន្មានឆ្នាំដែរបានថៃមានកូន?

ខ៖
មើលមិនបានដឹងថាចោលពោះបានប៉ុន្មាននោះទេបានមានកូននោះអត់ដែរបានចាំនោះទេនែកដូចជាបាន១ឆ្នាំអីដែរណែក។

ក៖ ចាស

ខ៖ មិនបានដឹងថាពេលនុងមានអត់ឬទេ!

ក៖ ចឹងថៃអឺ!...

ខ៖ កាលនុងបាន១ឆ្នាំចឹងហើយត្រូវហើយនៅឆ្នាំថោះ។

ក៖ ចាស!ចឹងអឺថៃដូចជាថៃបានមានកូនប៉ុន្មាននាក់នៅពេលមកដល់សព្វថ្ងៃនេះហ្នឹង?

ខ៖ កូនថៃប្រាប់ហើយ!ថាកូន៣។

ក៖ កូន៣ហ៎?

ខ៖ កូនវាមាន៤នាក់ប៉ុន្មានវាបានស្លាប់១ទៅហើយ។

ក៖ ចឹងកូនទី១មានឈ្មោះអីថៃ?

ខ៖ កូនទី១ឈ្មោះអឺ! ម៉ន ធារ៉ា។

ក៖ ហើយទៅគាត់ឥឡូវហ្នឹងបានទៅនៅឯណាដែរ?

ខ៖ បាននៅជាមួយថៃនៅក្នុងបន្ទុកហ្នឹង!

ក៖ អូ

ខ៖ អូបានសួរកូនទី១ហែសមិញ?

ក៖ ចាស!

ខ៖ សូមទោសច្រលំហើយកូនទី១ឈ្មោះ ដាលីន គេមានឈ្មោះថាដាលីនទេ។

ក៖ ហើយទៅកើតនៅថ្ងៃទីប៉ុន្មានដែរ?

ខ៖ អត់បានចាំដែរហាស៎ គ្រាន់តែបាននៅចាំថ្ងៃឆ្នាំវាគឺឆ្នាំរោង។

ក៖ អូនៅចាំឆ្នាំខ្មែរ!

ខ៖ ចាំឆ្នាំខ្មែរអើ!

ក៖ អីចឹងមានឈ្មោះថា ម៉ន ដាលីនចឹងឈ្មោះហ្នឹងមានអត្ថន័យយ៉ាងម៉េចដែរដែលចែបានដាក់អោយហ្នឹង?

ខ៖ អត្ថន័យហ្នឹងបានចេះតែដាក់អោយទៅតាមការស្រលាញ់ទេនេះ។

ក៖ ចឹងអត់មានថាបានបូកលេខឬក៏បានបូកអក្សរ ឬព្យញ្ជនៈអីណា!

ខ៖ អត់មានបានបូកនោះទេចែ។

ក៖ បានបូកអីបញ្ចូលគ្នាមកវាមានជាអត្ថន័យយ៉ាងម៉េចដែរ?

ខ៖ អត់នោះទេ!

ក៖ ឬក៏មានឈ្មោះខាងម្ដាយឪពុកអីយកមកផ្គុំគ្នាអីចឹងណា?

ខ៖ អត់នោះទេ!អត់បានរកអីចឹងនោះទេអូនអើយគ្មានបានទៅគិតនោះទេ។

ក៖ ខ្លះទៅរកគ្រូមើលដាក់ទៅអោយបានសុខសប្បាយអីចឹងណា!

ខ៖ អត់នោះទេចែអត់ដែលបានគិតអីចឹងសោះ!

ក៖ អត់ដែលបានគិតនោះទេ!

ខ៖
ចែចេះតែបានដាក់ទៅថាមើលឈ្មោះណាវាងស្រលាញ់ថាឃើញកូនរបស់គេមានឈ្មោះចឹងដូចជាល្អអីចឹងទៅប្រសើរអីចឹងទៅអ៊ីក៏បានដាក់អីចឹងទៅ។

ក៖ ចាស!ចឹងកូនទី១គឺជាកូនស្រី។

ខ៖ ស្រី

ក៖ ចាស!ចុះមកដល់កូនទី២?

ខ៖ កូនទី២គឺប្រុស។

ក៖ ចាសគេមានឈ្មោះអី?

ខ៖ ឈ្មោះធារ៉ា

ក៖ ឈ្មោះហ្នឹងគេមានអត្ថន័យយ៉ាងម៉េចដែរ?

ខ៖ អត់

ក៖ អត់ដែរហ៎?

ខ៖ វាមិនបានគិតអំពីអត្ថន័យតែគ្រាន់បានដាក់អោយវាវាងបានជូននឹងគ្នា។

ក៖ អូអោយជូនជាមួយហ្នឹងបង!

ខ៖ ហ្នឹងហើយ!

ក៖ ចាស!ចឹងកើតនៅថ្ងៃខែឆ្នាំកំណើត?

ខ៖ បានដឹងតែឆ្នាំកើត។

ក៖ ឆ្នាំណា?

ខ៖ ឆ្នាំមមែ

ក៖ ឆ្នាំមមែចាស!ហើយចុះមកដល់កូនទី៣?

ខ៖ កូនទី៣អាកា។

កៈ ឈ្មោះអីហ្នឹង?

ខៈ ឈ្មោះប៊ុកណាហៅក្រៅហៅតែស្រីលក្ខ័ៗ។

កៈ អូខាងប្រុសគេមានឈ្មោះ២!

ខៈ
ហើយអាប្រុស១នេះគេមានឈ្មោះវាម៉នធារ៉ាប៉ុន្តែហៅតែអាប្រុសព្រោះអីមានកូនប្រុសហ្នឹងតែ១នាក់ចឹងក៏ហៅចឹងឡើងធ្លាប់អស់ទៅហៅតែអាប្រុសៗទៅ។

កៈ ចាស!

ខៈ តែដល់ទៅក្នុងនាមត្រកូលនៅឯបញ្ជីជាតិរបស់វាគឺមានឈ្មោះថាម៉នធារ៉ាហ្នឹង។

កៈ ចាស!

ខៈ មិនដឹងជាមួយណានោះទេដែលបានយកត្រកូលឪពុកនេក?

កៈ ចឹងកូនទាំងអស់ហ្នឹងតើមានអត្តចរិតយ៉ាងម៉េចដែរ?

ខៈ កូនហ្នឹងសុទ្ធតែស្លូតៗ។

កៈ អត់មានអីច្រលឹសបឹសអីដែលធ្វើអោយឪពុកម្តាយពិបាកចិត្តទេ?

ខៈ អូមិនដែលធ្វើអោយឪពុកម្តាយពិបាកចិត្តនោះទេ។

កៈ អូចឹងកូនហ្នឹងវាក៏កន្លងធម៌ទាំងអស់គេថាចឹងណាវាកតញ្ញូ។

ខៈ កូននុងវាមិនដែលច្រលឹសបឹសតមាត់ម្តាយថាចឹងអីវាអត់ដែរ។

កៈ ចាសថាទៅតាំងពីជីតាអីមកដល់ចៅនេះក៏បានស្លូតបូតដែរ។

ខៈ
ហ្នឹងហើយ!កូននុងវាគ្មានទៅមើលងាយម្តាយឪពុកអីនោះទេវាគោរពឪពុកម្តាយគោរពឪណាស់។

កៈ ចាស!សព្វថ្ងៃកូនបានមានគ្រួសារបានប៉ុន្មាននាក់ហើយ?

ខ៖ បានមានគ្រួសារ២នាក់ស្រីៗហ្នឹង មាននៅអាកណ្ដាលប្រុស១នាក់។

ក៖ អោយគេនៅខាងណាខ្លះចៃ?

ខ៖
បើសិនជាមីស្រីនោះវាបានទៅដេរវាបានធ្វើការនៅរោងចក្រវាទៅនៅឯខាងឪពុករបស់វានៅឯខាងថ្នល់កែងយើងនេះ។

ក៖ ចាស!

ខ៖
នៅជាមួយឪពុកក្មេកម្ដាយក្មេករួចដល់ទៅធ្វើការគឺត្រូវទៅធ្វើការងារនៅឯកំពង់ឆ្នាំទៅជួលឡានគេទៅនៅក្នុង១ខែ១៥ដុល្លា។

ក៖ ហាក់ជិះឡានពេលព្រឹកទៅមកដល់ល្ងាចមកវិញ?

ខ៖ អើ

ក៖ អូឆ្ងាយណាស់ដល់កំពង់ឆ្នាំ!

ខ៖
អើបើធ្វើយ៉ាងម៉េចបើគ្នាទៅនៅឯនុងហើយគេបានធ្វើតេសជាប់ទៅធ្វើនៅឯនុង!អ្នកភូមិនៅឯនុងក៏គេមានទៅដេរនៅឯដល់នុងដែរ។

ក៖ រោងចក្រខាងអីគេ?

ខ៖ រោងចក្រដេរខាងខោអាវហ្នឹង។

ក៖ ខោអាវហ៎!

ខ៖ អើអាដេរខោកាបូយ!

ក៖ ហើយឈ្នួលឡាននុងគេយក?

ខ៖ ១៥ដុល្លាក្នុង១ខែ។

ក៖ នៅក្នុង១ខែគាត់ធ្វើការបានប៉ុន្មានដែរ?

ខ៖
នៅក្នុង១ខែហើយ!បើសិនជាថែមម៉ោងទៅបាន២០០ជាងទៅជូន២០០គត់ទៅជូនបាន២៤០ទៅអាហេយចេះតែនេះទៅ។

ក៖ អោយបានថ្លៃឈ្នួលឡាន។

ខ៖ អឹម

ក៖ ចឹងបានដាក់ម្ហូបទៅហា?

ខ៖
ពេលព្រឹកគេបានទិញអោយបាន១ពេលមិនដឹងថានៅពេលព្រឹកឬពេលណានោះទេ។អាហ្នឹងប្រហែលគេអោយបាយថ្ងៃត្រង់ហើយហ្នឹងហេស?

ក៖ អាពេលព្រឹកហ្នឹងប្រហែលជាបាយដោយខ្លួនឯងហើយ!

ខ៖ អាដល់ពេលថ្ងៃនេះហ្នឹងបាយរបស់ខាងរោងចក្របាន១ពេល។

ក៖ អាហ្នឹងគេបានចេញអោយដល់ពេលល្ងាចយើងបានមករកបាយផ្ទះយើងវិញ?

ខ៖ ហ្នឹងចឹង!

ក៖ ចាស!ដល់ពេលឥឡូវគេមានបានកូននៅ?

ខ៖ គេមានបានកូនបាន១នាក់ហើយ។

ក៖ ចឹងចៃបានចៅហើយណំ?

ខ៖ បានចៅ១នាក់ហ្នឹង។

ក៖ ចៅហ្នឹងស្រីឬក៏ប្រុស?

ខ៖ ចៅប្រុស មីពៅនុងគេបានកូន១នាក់ដែរគេបានចេះដើរហើយ។

ក៖ នុងប្ដីគេនៅខាងណាដែរ?

ខ៖ គេនៅឯខាងស្រុកចំការលើ។

កៈ អាហើយចឹងខាងប្ដីគេនុងរកអីដែរប្ដីនុង?

ខៈ កូនពៅប្ដីនុងវានេះវាបានដាំចន្ទី។

កៈ អូធ្វើចំការ

ខៈ ធ្វើចំការដែរ។

កៈ ចន្ទីបានផលមកបានលុយច្រើន។

ខៈ
មិនដឹងថានៅថ្ងៃណាបានផលនោះទេណាព្រោះលក់ដីនៅតាអុងនោះហើយបានទៅដាំនៅឯសីនៅឯខេត្តសៀមរាបឯណោះក្នុងស្រុកកំរុងដូអីគេនោះមិចទេ។

កៈ ហើយចឹងនៅឯនុងបានប៉ុន្មានហិច?

ខៈ បាន៧ហិច៧០អា។

កៈ ចឹងបានគាត់ផ្លាស់នុងដោយសារលក់បានថ្លៃ?

ខៈ លក់បានថ្លៃតែបន្តិចនោះទេបាន១០០០០ជាងជិតបាន២០០០០ដែរ។

កៈ ហើយដល់ពេលបានទៅទិញនៅឯណោះវាបានរាងធូៗ!

ខៈ នៅខាងណោះរាងតំលៃធូៗចឹងទិញវាបានច្រើនណា។

កៈចាសចឹងណា!

ខៈ តែវាមិនបានល្អដូចជានៅឯនុងនោះទេដីនុងវាអត់ជាងដីនៅឯនុងណាបន្តិច។

កៈ ចាស

ខៈ ដីនៅឯខាងតាអុងនុងវាជាដីក្រហមហើយដល់ពេលដីនៅខាងនុងវាជាដីរាងខ្សាច់។

កៈ ចាសមើលទៅវាមិនអីនោះទេព្រោះមកដល់ឥឡូវគេចេះរើសពូជម៉េចទៀតណ៎!

ខៈ អឺវាមិនអីនោះទេ។

កៈ សំរាប់ដីខ្សាច់ចឹង!

ខ៖
សំរាប់ចន្ទីនោះវាអត់អីទេ!និយាយទៅវាជាំនុងបានល្អគួសមដែរហើយទៅវាបានដាក់សណ្ដែក សៀងនៅក្នុងនុងដែរចឹងតែមិនបានដឹងថាវាយ៉ាងម៉េចនោះទេព្រោះអីឥឡូវនេះគេវាអត់ចូល ប្រហែលជាលេខទូរសព្ទគេអស់ថ្មឬក៏យ៉ាងម៉េច។

ក៖ គាត់មានដែលគេមកសួរសុខទុក្ខអីដល់ចែឯងដែរឬទេ?

ខ៖ អឺជួនកាលទៅវាបានគេមកជួនកាលឯងហ្នឹងបានគេទៅវិញទៅ។

ក៖ ចាស

ខ៖
ប៉ុន្តែឯងវាបានគេទៅប៉ុន្មានថ្ងៃនេះហ្នឹងវាអត់បានចូលចឹងមិនបានដឹងថាមានមូលហេតុអីចឹង ប្រហែលជាទូរស័ព្ទហ្នឹងវាខូចហើយមើលទៅព្រោះកូននុងវារពើសណាស់ វាដណ្ដើមទូរស័ព្ទអីហ្នឹងលេងចឹងមានតែខូចហើយបានគេទៅអត់ចូល។

ក៖ ចាស!ចឹងឪពុកចែដែរបាននិយាយពីជីដូនជីតាយាយដល់ចែបានស្ដាប់ដែស?

ខ៖
និយាយតើពេលគាត់នៅបន្ទុកជាមួយហ្នឹងម្ដាយរបស់គាត់ចឹងគាត់បានដើរតួចិញ្ចឹមប្អូនស្រីៗគាត់បានកាន់នង្គលរនាស់ទៅភ្ជួរដីនៅឯខាងរំទេរដើម្បីធ្វើថ្នាល់ត្រសកផ្អ ចិញ្ចឹមប្អូនៗរបស់គាត់សុទ្ធតែស្រីៗមានអឺសុន ស៊ីសែម អឺជា អីដាក់នង្គល បររទេះ គាត់ជាអ្នកដែលបានរាប់រងទាំងអស់ហ្នឹងប៉ុន្តែគាត់ប្រុសដល់ពេលគាត់មានបងប្អូន១នាក់ទៀត គឺចឹងហ៊ាងនោះប៉ុន្តែគាត់មិនសូវជា!...និយាយទៅគាត់មិនជាអ្នកដែលធ្វើចំការនោះទេគាត់ទៅ ដើរឡានធ្វើជាគ្រូឡានណាទៅ! គាត់នៅកាន់ចំការរនាស់អីនុងចឹងទៅ។

ក៖
ចឹងជីដូនជីតារបស់ចែនុងកាលនុងគាត់មានដែរបាននិយាយប្រាប់ដល់ចែថាប្រាប់របដែលបាន ធ្វើជាចំការអីចឹងណា គាត់ដូចថាបានរស់នៅក្នុងសង្គមនោះគឺនៅក្នុងសង្គមអីគេ?

ខ៖ មិនបានជាដឹងនោះទេព្រោះអីយើងនៅតូចៗនេក។ដឹងតែមុខពពតម្លេះកាលនុង។

ក៖ បាននៅមុខពពត។

ខ៖ ហឹម

កៈ កាលនុងមានបានកើតសង្គ្រាមអីទេហេស?

ខៈ នៅមុនពពតទៀត

កៈ កាលជំនាន់សង្គមរាស្រ្តនិយមនៅឡើយ នៅជំនាន់សម្ដេចតាយើងនេះ?

ខៈ អឺមប្រហែលជានៅក្នុងជំនាន់សង្គមរាស្រ្តជានិយមនឹងហើយ។

កៈ កាលនៅក្នុងសម័យនុងនៅសុខសាន្តនោះទេ។

ខៈ អឺមកាលនៅក្នុងសម័យនុងវានៅបានសុខសាន្តទេកាលជំនាន់នុងគាត់។

កៈ ចឹងអត់ទាន់មានបានកើតសង្គ្រាមនោះទេពេលជំនាន់នុង។

ខៈ
អឺមកាលដែលគាត់បាននៅជាអ្នកធ្វើចំការជាមួយឪពុកម្ដាយរបស់គាត់នុងកាលនុងបែបនៅសុខសាន្តនោះទេ!

កៈ
ព្រោះអីគាត់មានបាននៅរត់ឡានរត់អីនុងកាលនុងចឹងមានន័យថាប្រទេសជាតិកាលនុងនៅមានសុខសាន្តមកនៅក្នុងជំនាន់សម័យសង្គមរាស្រ្តជានិយមហ្នឹងហ៎។

ខៈ ហឹមបាននៅរស់សុខសាន្តនោះទេវាលំបាកមកនៅឯជំនាន់ចែហ្នឹងតែម្ដង!

កៈ នៅជំនាន់ពពត?

ខៈ មកនៅទាន់បានជំនាន់ពពតបានបន្តិចបានមកចាំនៅត្រង់ជំនាន់លន់
ណល់បន្តិចវាលំបាករហូត។

កៈ សង្គមរាស្រ្តជានិយមនឹងមកបានរបបលន់ណន់។

ខៈ ហ្នឹងហើយ!

កៈ ចាស!រួចហើយពីលន់ណន់ហ្នឹងហើយបានចូលមកជំនាន់ពពត?

ខៈ ហ្នឹងចែបានទាន់ត្រង់ហ្នឹងវាលំបាក!

កៈ ចែចំលំបាករហូត!

ខ៖ ហ្នឹងចែចំលំបាករហូត អកុសលមករហូត មកជីវិតរបស់ចែហ្នឹង
វាបានវេទនាណាស់កាលនុងគេអោយធ្វើកងកុមារបានបែកពីម្តាយហើយបានមកដេកនៅរួមនុងកាលនុងនឹងឪពុកម្តាយហើយពេលនុងគេបានបញ្ជូនអោយទៅធ្វើកងកុមារនុងកាលនុងវានៅរាងតូចជាគេ យំរាងតែយប់។

ក៖ កាលនុងចែមានអាយុប៉ុន្មានកាលនុង?

ខ៖ កាលនុងតាមចាំគឺអាយុ៩ឆ្នាំនៅឡើយនោះទេ មើលដូចជាបានចូល១០ហើយ។

ក៖
មើលចែចូលរៀបរាប់នៅក្នុងសម័យពពតហ្នឹងមើលថាតើពេលដែលចែគេបានអោយនៅដាច់ពីឪពុកម្តាយនុងគេអោយជួបឪពុកម្តាយដែរឬទេហើយចំពោះការងារគេអោយធ្វើយ៉ាងម៉េចដែរ?

ខ៖ វាលំបាកណាស់។

ក៖ មើលគេអោយចែទៅនៅឯកន្លែងណាខ្លះមើលចែរៀបរាប់មក!

ខ៖ ចែកាលពីមុខដំបូងគេបានអោយចែមកដេកនៅឯភូមិតាថ្លាង
ផ្ទះយាយសុខចេងហ្នឹងណា។

ក៖ ចាស!

ខ៖ កាលនុងចែក៏នៅរាងតូចដែរ
មិនទាន់ដុះដោះនោះទេ!នៅស្ងិតរញ៉េរនុងគេបានចែកអោយចាន១ម្នាក់ៗនៅចែកបាយនៅឡើយកាលនុងគេនៅបានចែកបាយនៅរួមរួចចឹងទៅស្រាប់តែគេថាអោយទៅឯជំឡូ
នៅក្នុងកងចល័តកុមារដែលគេបានប្រមូលទៅប្រក់ស្លឹក
ទៅនៅឯចំការនុងដំបូងគេអោយជីករន្ធដៅដាក់ដាំកូនអំពៅដល់ហើយទៅពេលនុងនឹកម្តាយៗនឹក
ព្រោះអីកាលនុងទើបតែបានអាយុបាន៨ឆ្នាំកាលនុងថាមិនទាន់បានចូល១០នោះទេកាលនុង
ព្រោះអីនៅតូចជាងគេ ចំណែកឯគេក្រមុំៗឯវាស្តើងហើយវាស្ងិតជាងគេទៀត។

ក៖ ចាស!

ខ៖
ចឹងមានបានទៅធ្វើអីនៅជាមួយគេនុងបានហត់ណាស់បានកាប់តែរន្ទដៅ១ទៅ២នុងកាលនុង
ហត់ចឹងងាប់ហើយទៅដាំអំពៅ រួចហើយទៅគេអោយយើងទៅបាច់ទឹកដាក់នៅក្នុងស្រូវ!

ក៖ ចាស

ខ៖
ដល់ពេលរួចហើយពីបាច់ទឹកដាក់នៅក្នុងស្រូវទៅគេអោយជីកអាប្រឡាយលើកដាក់នៅក្នុងទំ
នប់នោះគេបានដាក់ម៉ែត្រអោយដល់ឯង២ម៉ែត្រគីប
២ម៉ែត្រនោះគេអោយជីករន្ទដៅនៅក្នុង១ថ្ងៃហ្នឹងហើយជីកអោយរួច...

ក៖ អោយជីកតែម្នាក់ឯង?

ខ៖ ចឹងណាហើយគេបានអោយមកចាក់ជាទំនប់ទៀត
ហើយគេបានប្រាប់ថាអោយធ្វើការអោយបានរួចទើបគេអោយហូបបាយ។
ដល់ពេលរួចបាយពេលល្ងាចហើយគេចូលទៅអស់គ្នានៅតែឯងព្រោះអីគេក្រមុំៗនៅតែឯង
ព្រោះអីតូចជាងគេដល់ពេលចឹងឯបានទៅបង់កំលាំងហើយព្រោះអីគេធំឯងតូចចឹងហើយកា
លនុង២ម៉ែត្រហ្នឹងតែឯង អើដល់ពេលតែឯងអត់រួច
ដល់ពេលអត់រួចចឹងគេនាំគ្នាបានឡើងអស់ គេបានទុងស្គរវ៉ៃជួងមាំៗនៅភូមិនុង
ហើយអាហ្នឹងវាបានចាប់ផ្តើមជំហានទី១ហើយ។

ក៖ ចាស

ខ៖
ហើយស្រាប់តែថៃហ្នឹងបានយំតែម្តងព្រោះអីអត់ហ៊ានឡើងលើព្រោះអីគេស្តីអោយគេទិចទាន
ចឹងធ្វើម៉េចគេប្រើហើយអត់ធ្វើរួចនោះទេ
ឡើងហើយនៅម៉េចហ្នឹងកើតមើលវាអត់ឃើញ!ហឹស!ដល់ពេលដែលឡើងមកនុងបានស៊ីបា
យក្រោយគេហើយពេលគេដួសបបរមកនុងវាឡើងរវកក្លួក
ក្រោយគេហ្នឹងហើយមិត្តឯងខ្វិលមកក្រោយគេ ហើយធ្វើការក៏ក្រោយគេ
ចឹងគេអត់មានអាណិតយើងតូចជាងគេនោះទេណា!

ក៖ ចាស!

ខ៖ ចឹងថៃយំនៅឯតុហ្នឹងណា!
ដាក់ចានបបរទៀតណាដល់ពេលហើយទៅដល់ពេលនិយាយមកដល់ពេលឥឡូវនេះហ្នឹងចង់តែយំទៀតហ្នឹងព្រោះអីកាលនុងមកវាកំសត់មែន។យំគេបានប្រជុំនុងរាល់តែថ្ងៃហ្នឹងព្រោះអីអោយតែដល់មុនដេកគេត្រូវហៅទៅប្រជុំសិន ព្រោះអីគេត្រូវហៅមិត្តណាទៅកសាងតើមិត្តណាដែលបានធ្វើការលឿន ហើយមិត្តណាធ្វើការមិនបានគ្រាប់ផែនការចឹងតើនរណាគេបានធ្វើគ្រាប់ហើយតើនរណាគេអត់បានធ្វើគ្រាប់។

ក៖ ចាស!

ខ៖ បើសិនជាធ្វើមិនគ្រាប់គេហ្នឹងយកទៅកសាង។

ក៖ ចាស

ខ៖ហើយគេសុទ្ធតែអោយយកដាក់ខ្លួន
សូមដាក់ខ្លួនអោយបងប្អូនទាំងអស់ទិចទានបើសិនជាខ្ញុំធ្វើទៅលឿនឬក៏មិនបានលឿនខុសត្រង់ណាអីវាម្តងម្នាក់អោយយើងដាក់ខ្លួន។

ក៖ ចាស!

ខ៖ ហើយទៅចេះតែដាក់ហើយ។

ក៖ អាហ្នឹងដូចថាអោយយើងសារភាពកុំហុសហ្នឹងណា។

ខ៖ អើម
ដាក់ទៅឯងបានសរសើរគុណសម្បត្តិរបស់គេថាគេបានលើករួចគេចំណាប់ចំនួនដល់ពេលមកឯងវិញមិត្តឯងឃើតជាងគេមិនសមហូបបាយនោះទេធ្វើមិនដែររួចគ្រាប់ម៉ែត្រគ្រាប់ធឹងហ្នឹងគេនោះទេ យំទៀតហើយ។

ក៖ ចាស!

ខ៖ គេយកទៅកសាង
កំសត់ណាស់កំសត់ដល់ទៅមែនទែនណាគេបានអោយដេកនៅឯផ្ទះអាផ្ទះមណ្ឌលកុមារគេនុងនៅផ្ទះរបស់ពូស៊ីមនៅឯខាងចំការឡឹកនៅនុងគេសំរាប់ដាក់កុមារមានមេដោះគេអោយដេកនៅឯផ្ទះនុង។

ក៖ ចាស

ខ៖ រួចដល់នេះទៅនិយាយពីគ្រូហៀង
គ្រូហៀងកូនតាខ្វង់ហ្នឹងណាដាក់ដាំបាយគាត់ជាចុងភៅគាត់បានអាណិតបាយរបបក៏ស៊ីវាមិនបានឆ្អែកគេបានចែកអោយគេបានធ្វើបាបហើយស៊ីវាមិនបានគ្រប់គ្រាន់ព្រោះអីកាលនុងយើងតូចជាងគេចឹងក៏គាត់បានចេះតែលួចអោយបាយជ្រូកបាយក្តាំងយើងមកអោយ។

ក៖ អូកាលនុងគាត់មានចិត្តធម៌មេត្តា។

ខ៖
អូសមកដល់សព្វថ្ងៃនេះហ្នឹងនៅដឹងគុណគាត់បានមកដល់សព្វថ្ងៃនេះហ្នឹងនៅទុកគាត់ដូចជាឪពុកធម៌។

ក៖ ចាសៗ!

ខ៖ គ្រូហៀងហ្នឹងបងគ្រូចេន ម៉ែចៃឆៀងនេះ
នៅចាំដល់ឥឡូវហើយរាប់អានគាត់ដល់ឥឡូវហ្នឹងដែរ។

ក៖ ចាស!ៗ

ខ៖
គាត់ក៏មិនភ្លេចយើងហើយយើងក៏មិនដែរបានភ្លេចគាត់អីនោះទេដល់ពេលបានការចៃប្រាប់គាត់ហើយគាត់បានមកដែរ។

ក៖ ចាសចៃ!

ខ៖ បើសិនជានិយាយអំពីប្រវត្តិនោះនិយាយទៅថាវាច្រើននិយាយវាមិនចេះអស់នោះទេមិនអស់ទេកំសត់ណាស់អូនអើយនៅឯលើរួចទៅគេបានអោយទៅរហូតដល់កងត្រណឹងព្រែកកុយឯណាន់ទៀតកាន់តែឆ្ងាយពីឪពុកម្តាយនិយាយថានឹកឃើញយំ
ពេលហ្នឹងឃើញឡើងបានធ្លាប់ដេកជាមួយម្តាយចេះដឹងឃើញឡើងយំៗទៅបន់រហូតដល់តែភ្លឺ។

ក៖ ហើយទៅដល់នុងគេបានអោយចៃធ្វើការអីទៀត?

ខ៖ គេអោយនែកអោយច្រូតស្រូវនៅឯបាទបឹង ទៅនៅឯបាទបឹងកងតាណឹងឯណា គេអោយច្រូតស្រូវនៅឯភូមិមាត់ទន្លេហ្នឹងចឹងម៉ាស្រូវហ្នឹងគេទៅធ្វើនៅឯបឹងណាណាំហើយយើងកាលនុងដូចជាពីចុងព្រៃកមកចំកែងតួយចឹងវានៅឆ្ងាយពីភូមិ។

ក៖ ចាសនឹងនៅមាត់បឹងហើយហ្នឹង។

ខ៖ ហ្នឹងគេហើយអោយធ្វើពេងអីនៅឯនុងនៅកណ្តាលអីនុងបានដេកនៅឯនុង គេហើយអត់មានដែរបានស្គាល់ភូមិអីនោះទេ។

ក៖ ចាសកាលនុងនៅក្នុងព្រៃ។

ខ៖ ដេកនៅក្នុងព្រៃដែលបានទៅធ្វើស្រែនៅឯនុងតែម្តងអើ។

ក៖ នៅឯបឹងនុងគេអោយបបរអាហារយ៉ាងម៉េចដែរពេលនុង?

ខ៖ ប៉ុន្មានកាលនុងយើងវាបានរាងគ្រាន់បើគឺនៅឯនុងគេបានអោយយើងបានហូបបាយឆ្អែក នៅនោះគេអត់មានហូបបាយវាស់វែកនៅចំការឡើកនោះទេកាលនុងបានតែ១វែកនោះទេ។

ក៖ ចឹងគេបានអោយយើងបានហូបសេរីបានមួយឆ្អែកៗ!តែម្តងហាំ?

ខ៖ អឹសគេបានអោយយើងបានហូបសេរីហើយស្លគេមានសមរម្យជាងនៅឯខាងយើង។

ក៖ ចុះគេមានបានស្លអីគេខ្លះដែរទៅចែ?

ខ៖ នោះនុងទោះបីជាគេស្លម្ជូរក៏ដោយក៏គេដាក់ព្រលឹត ប្រហុកអោយបានរាងប្រៃដែលប៉ុន្តែបើសិនជាស្លនៅឯខាងយើងនេះវាស្លសាបណា សំឡនៅខាងយើងនេះគេឡសាបណាស់។

ក៖ នៅឯខាងយើងនេះខ្ញុំបានលឺចាស់ៗគាត់បានប្រាប់ថាអត់មានបាយនោះទេ។

ខ៖ ចាស!វាកំសត់ជាគេ។

ក៖ កាលនុងមានតែបបរហើយឡើងរាវកក្លូក។

ខ៖ បបរនុងហើយមានដាក់លាយជាមួយព្រលឹតទៀត។

ក៖ ដាក់ទៅហើយពេលបានប្រមូលទៅដាក់បានតែ១ស្លាបព្រានោះទេគេថាវាតឹងណាស់។

ខ៖ លាយព្រលឹមដល់ពេលប្អូនចៃទៅហូប ដែលប្អូនចៃមួយនាក់ឈ្មោះ មីកាទូចហ្នឹងណា! ថាចៃអើយខ្ញុំស៊ីវាមិនកើតនោះទេវាអោយស៊ីសុទ្ធតែព្រលឹមនេះ។

ក៖ ចាស!

ខ៖ រួចវាសំរិតហើយពេលនុងខ្ញុំក៏អត់មានបានលបមើលគេដែលមានប្រធានគេលបមើលណា ហើយខ្ញុំវាមិនបានទៅលបមើលគេឯណាដល់ចឹងទៅមានគេលបមើលហើយគេទៅរាយគេប្រាប់ ពូដិនៗនេះ
ដែលជាគ្នាយើងហ្នឹងសព្វថ្ងៃនៅឯខាងភូមិថ្មីនេះបានរាយការណ៍ថាមើលប្អូនមិត្តងឹមកំពង់តែសំរិតទឹកបបរហ៎
ខ្មាំងហើយអត់មានហូបទាំងអស់នោះទេហើយអត់ទៅលុតដំទេ?ស្រាប់តែមិត្តឌីនហ្នឹងគេបានមកដល់គេសួរថាមិចក៏អត់ហាតទឹកបបរចឹង?ហើយខ្ញុំក៏ថាមិត្តអើយប្អូនរបស់ខ្ញុំទេ មិនមែនខ្ញុំទេ! ខ្ញុំដឹងទាំងអស់ថាចឹង
ថាខ្ញុំដឹងទាំងអស់មិត្តឯងហ្នឹងគឺជាខ្មាំងហើយត្រូវយកទៅលុតដំហើយព្រោះអីមិត្តឯងអត់ហាតទឹកបបរនោះទេយកទឹកបបរចោល។

ក៖ ចាស

ខ៖ ហើយគេបានសួរដល់ខ្ញុំថាជាកូនពីណា?ខ្ញុំក៏ថាកូនតាស៊ឹម
ហើយគេក៏បានសួរខ្ញុំទៀតថាផ្ទះនៅឯណា? ខ្ញុំប្រាប់គេថាផ្ទះខ្ញុំនៅឯណោះនៅខាងជើង។
ពេលនុងខ្ញុំលែងស៊ីចូលហើយព្រោះអីខ្ញុំខ្លាចគេសម្លាប់ដល់ពេលចឹងខ្ញុំសងំនៅឯក្នុងព្រៃហ្នឹងឡើងដល់៦ខែ!
ម៉ែអើយ!ខ្ញុំលែងហ៊ានទៅស៊ីហើយគេរកចាប់ខ្ញុំរួចទៅពីណាក៏គេថាខ្ញុំគេចាត់ខ្លួនដែរ!
តែកាលនុងខ្ញុំវាបានទៅសងំនៅឯសង្កែងទួយនៅឯខាងតាក្តាកឯនុសនៅឯខាងចំកែងទួយឯណោះ!
ដល់ពេលយប់ទៅបានលូនមកទៅហើយប្រាប់ម៉ែថាខ្ញុំបានលួចបានបបរបន្តិចមកអោយស៊ីហើយដល់ពេលទៅខ្ញុំប្រាប់គាត់ថាខ្ញុំលួចបានបបរបន្តិចយកមកស៊ី
នៅឯខាងចំកែងទួយនេះវិញណែក
ហើយពេលនុងគេអត់មានមករកខ្ញុំនោះទេ!ដល់ពេលយូរទៅស្រាប់តែខ្ញុំគិតថាយូរហើយចឹងស្រាប់តែអត់គេអីនោះទេចឹងបានខ្ញុំចេញមក ដល់ពេលខ្ញុំបានចេញមកមីក្អួន
មីសៀងអីឪគេអីបានសួរថាគេមានបានរកចាប់ហងទៅគេមានបានដាក់ច្រវ៉ាក់ហងដែស?ហើយប្រាប់គេថាខឹបៗថាគេមិនបានចាប់អញនោះទេពេលនុងអញបានរត់ទៅពួន

ពេលនុងបាននិយាយទៀតថាគេអត់បានចាប់នោះទេប្រាប់គេថាអញបានរត់នៅពួនទៀតណា!

ក៖ ចាស

ខ៖ ថាពីក្តាកទៅឯខាងចំកែងទួយហើយពីខាងចំកែងទួយទៅដល់ក្តាកនុងណា កាលនៅពីដើមហ្នឹងមានដើមមួយវាធំណាស់ដែលនៅឯខាងនុងណា។ ថាវានិយាយមិនបានអស់នោះទេកាលនៅក្នុងជំនាន់ពពតនោះណា!

ក៖ ចាស!

ខ៖ កាលនៅក្នុងជំនាន់ពពតខ្ញុំគឺបានកំសត់តែមែនទែន ហើយមានប្អូន១នាក់ដែលស្លាប់ទៅហ្នឹងគឺបានស្លាប់ដោយវេទនាបំផុត គេយកទៅដាក់នៅឯមណ្ឌលហើយមេមណ្ឌលហ្នឹងគេបានចំណែករបស់គេមកគេបានចែកអោយដល់កូនគេហើយបបរនុងគ្រាប់ៗពោត ចឹងកាលនុងវាមិនទៅបានមើលកូនយើងអីវាបានបាក់ទឹកដោះនោះចឹងវាហើម វាបានទៅជាហើមស្រកហើមស្រកចឹងក៏វាបានស្លាប់បាត់ទៅ!

ក៖ រួចម្តាយវិញ?

ខ៖ ម្តាយនុងក៏បានទាស់ទៀតព្រោះគេទើបតែបានកូននៅខ្ចីហើយគេបានប្រើអីស្ទូងទៀត ហើយចឹងបានពេលដែលបានដាច់ភ្លាមៗនុងគាត់បានហើមហើយបានវង្វេងដើរពេញភូមិហ្នឹងណាហើយគេថាគេឆ្កួត ហើយគេថាវាព្រាយក្រលាភ្លើង។ ចឹងកាលនុងគេបានថាគាត់ឆ្កួត។

ក៖ ចឹងកាលនុងគាត់បានទឹមតែសរសៃនៅខ្ចីហើយគេបានប្រើគាត់ទៅស្ទូង?

ខ៖ ហ្នឹងហើយ!វាថាប្រហែលជាកើតព្រាយក្រលាភ្លើងនុងទេកាលនុងអត់បានដឹងអីផងនុងកាលនុង។

ក៖ ចាស!

ខ៖ ដល់ពេលចឹងគេបានប្រើគាត់ទៅហើយគេបានអោយគាត់ទៅដេកនៅឯពេទ្យអុំអានហ្នឹង ដល់ពេលបានខ្លាំងមែនទែនហ្នឹងគេបានបញ្ជូនគាត់ទៅដល់ឯខាងពាម

ដល់ពេលហ្នឹងគាត់បានប្រាប់ថាបានមើលឃើញថាយក្សចឹងគាត់ក៏បានរត់តាទៅក្រៅមានលោតចេញតាមអាមាត់បង្អួចពេទ្យនៅឯនុង!

ក៖ ចាស!

ខ៖
គាត់ថាមើលលវារត់មកតាមឯងហើយ!ស្រាប់តែគាត់រត់មកដល់បានជួបអញហើយកាលនុងអញបានមកពីខាងស្រែវិញនុងកាលហ្នឹងក៏បានជួបមកត្រឹមផ្ទះអាណាក់យើងនេះហើយអត់មានស្គាល់យើង!
គាត់ថាអញគ្មានដៃរស្គាល់ទេលែងដៃអញទៅហើយមើលមានយក្សធំណាស់វាមកហើយតាមដេញចាប់អញ គេរកសម្លាប់អញណា។

ក៖ ចាស

ខ៖ ហួស!កំសត់ណាស់អារឿងខ្មោចម្ដាយខ្ញុំវិញ
ចឹងបានថាគាត់បានទំរនទំរាតាំងពីជំនាន់ពពតនុងមកហើយចំណែកឯជីនៅខាងតាកុតហ្នឹងវិញក៏គាត់បានរែកដែលកាលនុងគាត់បានរែកតាំងពីមុនកូនខ្ញីនោះម៉េស!

ក៖ ចាស

ខ៖ កាលនុងដូចថាគាត់បានបាក់ចឹងតែម្ដងហ្នឹងណា។

ក៖ ចាស

ខ៖ គាត់បានបាក់នៅពេលបានស៊ីបបរព្រលឹតត្រកួនហ្នឹងទៀត!

ក៖ ចាស

ខ៖
គាត់បានហើមហើយស្រកអាក្រក់ហ្នឹងហើយកាលនុងវាអត់មានបានបបរអីបានដាក់អំបិលទៀតកាលនោះនៅក្នុងសំឡនុងហ៎។

ក៖ ចាសប៉ារបស់ខ្ញុំគាត់ហើមដែរបានដើរឡើងត្រិកត្រុយ!

ខ៖ សំឡនុងវាសាយនោះទេ!

កៈ
កាលនុងប៉ារបស់ខ្ញុំគាត់បានមានឈ្មោះនៅក្នុងបញ្ជីហើយនុងកាលនុងនៅសល់តែប៉ុន្មានថ្ងៃទៀតនុងគេយកគាត់ទៅវ៉ៃដែរហើយហ្នឹងតែស្រាប់តែខ្វះតែ២ទៅ៣ថ្ងៃទៀតបានដាច់បាត់ទៅ។

ខៈ
ខ្ញុំក៏មានដែលគឺយាយរបស់ខ្ញុំហ្នឹងមានឈ្មោះថាលោកយាយយឿមានប៉ុន្មាននាក់ហើយមានទាំងឈ្មោះរបស់ប៉ាអីនុងទៀតថាត្រូវដល់ថ្ងៃហើយស្រាប់តែវាបានដាច់ទាន់នេះឈ្មោះរបស់គាត់នោះគឺវាមានហើយឈ្មោះម្ដាយហ្នឹងប៉ានុងព្រោះអីគាត់បានឈឺហើយធ្វើការមិនកើត។

កៈ ចាស!

ខៈ អឺស!ខ្ញុំកំសត់ដល់ហើយវាច្រើនណាស់ប៉ុន្តែចៃវានិយាយទៅវានៅមិនទាន់អស់នោះទេ។

កៈ ចាស!

ខៈ កំសត់មែនកាលនុងវាវេទនាមហាសែន គេបានធ្វើបាបខ្លាំងមកដល់រូបចៃហ្នឹង។ ឈ្មោះមិត្តអានៗនុងគាត់នៅឯទឹកចេញឯណោះពេលនុងគាត់ជាប្រធាន។

កៈ
កាលនុងចៃបានជួបនៅក្នុងសម័យជំនាន់ពពតនុងគឺថាចៃបានមានគំនិតមួយចង់ចាំដែលមិនអាចបំភ្លេចបានណា!

ខៈ ចង់ចាំណាស់ដល់សព្វថ្ងៃនេះហ្នឹងបាននិយាយប្រាប់ដល់កូនណា។

កៈ ចៃបានប្រាប់កូនថាម៉េចដែរទៅចៃ?

ខៈ អើវាថាបានឈឺចាប់ហ្នឹងនៅត្រង់ថាវាបានអោយយើងធ្វើហើយបានធ្វើទារុណកម្ម។

កៈ ហើយកាលនុងគេមិនបានអោយយើងបានស៊ីគ្រាប់គ្រាន់អីចឹងនេសចៃ អត់មានបានអោយជួបជុំឪពុកម្ដាយ ហើយបានអោយបំបែក!

ខៈ អឺម!ដូចជានឹកឡើងវាអាណិតខ្លួនដូចថាកាលនៅក្នុងសម័យនុងហេតុអ្វីក៏វាកាចមានកម្មអីក៏កម្មទាំងអស់គ្នាចឹងចេះតែបានគិតចឹង!
បើសិនជាកម្មអីបានជាកម្មឡើងមួយប្រទេសកម្ពុជាយើងនេះចឹង?

កៈ កម្មអីអាហ្នឹងវាព្រះពុទ្ធទំនាយ!

ខ៖ ពុទ្ធទំនាយចៃបានគិតចឹងដែរអើ!

ក៖ បើសិនជាពុទ្ធទំនាយវាត្រូវតែដល់ចឹងតែម្តងហ្នឹង។

ខ៖ អឺ

ក៖ ដូចថានៅឯកន្លែងនុងដូចថាគេថាអត់អោយមានពុទ្ធសាសនាអីចឹងណា ហើយគេបានថារុះផ្ទះអីនុងអាម៉េចដែរនោះទេចាស់ៗបានប្រាប់កាលនុងខ្ញុំដូចជាមិនសូវបាន ចាំហ្នឹងដែរ!

ខ៖ រុះផ្ទះចេញទៅធ្វើផ្ទះស្បៅអីនោះមិចទេ!អានុងវាបានចូលនៅក្នុងជំនាន់នុងហើយ!

ក៖ ថាមានផ្ទះអត់មានមនុស្សនៅហើយមានផ្លូវអត់មានមនុស្សដើរនោះមិចទេ!

ខ៖ អឺហើយកាលនុង!

ក៖ មានលុយអត់មានមនុស្សចាយ!

ខ៖
នុងហើយនៅជំនាន់នុងហើយហ្នឹងហើយបែបសាសនានុងហើយដែលមានពុទ្ធទំនាយចំកន្លែង នុងហើយនេះ។

ក៖ ចាស

ខ៖ អញបានចាំ!

ក៖
ពុទ្ធទំនាយនុងវាចឹងដែលនុងវាចឹងហើយមែនបើចៃម៉ាក់របស់ខ្ញុំអីគាត់បានប្រាប់ខ្ញុំដែលនឹង ណាព្រោះអីពេលនុងវាទៅខ្លាចអីអោយកូនក្មេងកាន់កាំភ្លើងមិនទាន់ដឹងក្តីអីហើយយកទៅវ៉ៃ ចោលរួចខ្លួនឯងបានរៀនសុទ្ធតែជាបញ្ញវន្តចេះដឹងសុទ្ធតែជាសាស្រ្តាចារ្យ។

ខ៖
កាលនុងនៅឯចំកែងទួយនុងបានបកមកវិញដើម្បីមកហូបបាយមកដល់ឯខាងរោងបាយយើង ស្រាប់តែនៅត្រង់ផ្ទះចៃស៊ីមយើងហ្នឹងហើយចៃបានឃើញប្រហែលជាមានមនុស្ស១០បានចង់ ដៃហ្នឹងទៅខាងក្រោយហើយបានយកទៅចង់លាបសែកហើយស្រាប់តែគេដូចឃើញប៉ានៅខា ងក្រោយ!

ក៖ ហឺស!

ខ៖
ហឺស!ពេលនុងស្រាប់តែគិតថាអញអើយមើលទៅអញប្រហែលជាអត់បានមានប៉ាហៅនោះទេ!តែស្រាប់តែមករកប៉ាឃើញប៉ានៅកន្លែងតែមកដល់ឥឡូវនេះគង់តែប៉ាគាត់អត់បាននៅរស់កាលនុងបានដេកភ័យទុកថាមិនដឹងថាថ្ងៃណាដែរគេបានមកយកអញនោះទេព្រោះអីបើសិនជាយកប៉ាអញទៅថ្ងៃណាមួយក៏គេគង់តែហ្នឹងយកអញទៅដែរហើយណ៎ចឹងត្រូវរត់ទៅឯណាដែរទៅណ៎កាលនុងចេះតែបានគិតថាចឹងចេះគិតថាចឹងតាំងពីតូចម៉េចហើយណ៎។

ក៖ ចាស

ខ៖ អាហ្នឹងគេទេតែនិយាយថាភ័យបានត្រៀមទុកហ្នឹងតែម្ដង។

ក៖
កាលនុងបើសិនជាមនុស្សដែលបានរួចផុតពីរបបប្រល័យពូជសាសន៍នុងមកគឺជាមនុស្សដែរមានបុណ្យហើយណែសចែណ៎?

ខ៖ អឺម!ចែក៏បានគិតថាចឹងដែរពេលហ្នឹងត្រូវតែស្រលាញ់គ្នាណាវាពិបាកណាស់។

ក៖
ចាសចែចឹងមុខហ្នឹងបញ្ចប់ចែមានពាក្យពេចន៍អ្វីដើម្បីធ្វើការផ្ដាំផ្ញើដល់កូនចៅនៅជំនាន់ក្រោយអំពីជីវៈប្រវត្តិដល់ជូរចត់ដែលជាជិវៈប្រវត្តិខ្មោយង់ខ្នងហ្នឹងហែស?

ខ៖
ហ្នឹងចែសូមផ្ដាំដល់កូនចៅឬក៏ក្មេងៗចៅៗអោយហ្នឹងថាចែនៅក្នុងជំនាន់នុងវាវេទនាណាស់បើជូនជាវាមិនដែលបានដឹងអីចឹងដូចជាមីលក្ខ័អីវិញវាបានសួរថាពពតនោះមានសម្បុរយ៉ាងម៉េចដែរតើគេមានក្បាលពោះកំប៉ោងៗហ៎?ខ្ញុំក៏ប្រាប់ថាអត់នោះទេគេធម្មតាទេ។

ក៖ អូ

ខ៖
មីលក្ខ័វាសួរវាបានថាតើគេមានក្បាលពោះកំប៉ោងៗហើយមានមាឌធំហ៎ចែ?ថាមិនមែននោះទេធម្មតាទេតែគ្រាន់តែកាលនុងគេហៅថាជាសង្គមពពត។

ក៖ មនុស្សយើងហ្នឹងក៏ប៉ុន្មានមនុស្សយើងនឹងចិត្តខ្មៅ ចិត្តដេរឆា!

ខ៖
មិនដឹងជាមិចទេដូចចង់តែរកសម្លាប់គ្នាឯងហ្នឹងតែម្តងហើយសំលៀកបំពាក់ពណ៍អីគឺគេបានបំបាត់អស់ហើយកូន។

ក៖ ចាស

ខ៖ ហើយសក់អោយកាត់ខ្លីនៅត្រឹមតែកនោះទេ។

ក៖ ខោខ្មៅអាវខ្មៅហើយអត់អោយទុកសក់វែងនោះទេ
ទុកតែខ្លីៗនៅត្រឹមកអីហើយសំរាប់ប្រុសៗគេបានបង់កក្រមា។

ខ៖ វាធ្វើតែចឹងទាំងអស់ចឹងមក។

ក៖ ហើយមានប្រាប់វាដែសថាបើសិនជារៀបការវិញសុទ្ធតែរៀបការ៥០គូនៅក្នុង១ថ្ងៃ។

ខ៖
មានបានប្រាប់ដល់វាចឹងដែរថាគេបានរៀបកាលនុងសុទ្ធតែ៥០គូកូនអើយ!អញបានប្រាប់ដល់វាចឹងវាបានប្រាប់ដល់យើងវិញថាបើសិនចឹងខ្ញុំដូចជាភ័យដល់ហើយ
ហើយខ្ញុំបានអាណិតម៉ែឯងណាស់ណែក។

ក៖
ពេទ្យយើងក្បត់អង្គការពេលថាយើងឈឺអីចឹងបានទៅដេកនៅឯក្នុងពេទ្យគេបានចាក់ទឹកដល់ពេលបានចាក់ទឹកអោយចឹងងាប់តែបណ្តោយ
ដូចខ្ញុំមានកុង១គាត់ទៅហើយពេទ្យគេចាក់ទឹកក៏ងាប់។

ខ៖ គេចាក់នុងកាលនុងចុកនៅក្នុងកំប៉ុងទឹកក្រូច
ហើយគេរុំដបជ័រកៅស៊ូចឹងណាគេបានបូមចាក់។

ក៖ ហែស!

ខ៖ ហើយវាចុកវាចុករកតែម៉ែវាហើយមិនបានដឹងថាថ្នាំបេដូលអីវានោះទេ! ឈឺអីក៏បេដូល!

ក៖ ខ្ញុំលឺចាស់ៗបានប្រាប់ថាបើសិនជាមានថ្នាំវិញគឺថ្នាំគេមូលៗដូចគ្រាប់អាចម៍ទន្សាយ ។

ខ៖
មិនបានដឹងទេនេះនៅពេលនុងគេបានបង្កើតពេទ្យចឹងមិនដឹងថាអីគេបានជាន់ស្លឹកនុងអោយ
ម៉ត់ទៅគេយកមករែងហើយគេរុំមូលប៉ុនចុងចង្កោះ។

ក៖ អឺស

ខ៖ អានុងថ្នាំពាគអាចម៍!

ក៖ អូនៅឯនុងគឺជាកន្លែងដែលគេបានផលិតថ្នាំពេទ្យ!

ខ៖
ហ្នឹងហើយកាលនុងចៃបានមើលឃើញកន្លែងនុងមានគេចំហ៊ុយអីទៀតសំរាប់យកមកចាក់នុង
។

ក៖ អូ

ខ៖ ហើយចឹងហើយបានចាក់ទៅវាងាប់នោះ។

ក៖ អូចាស

ខ៖
ហើយចៃបានឈឺអីចឹងទៅក៏បានទៅគេបានអោយថ្នាំអាចម៍ទន្សាយយកមកគេបានបំបែកមើ
លទៅអាស្លឹកតំបែកយើងហ្នឹងហើយគេបានយកទៅបុកហើយគេយកទៅកិនទៅ
ហើយគេបានយកទៅលុនហើយដាក់ហាលថ្ងៃទៅរួចដាក់ដបទៅកាលនុងវាមានតែថ្នាំណាហ្នឹ
ងគ្មានថ្នាំពេទ្យអីដូចជាយើងនៅពេលឥឡូវនេះទេដូចមានពណ៌សម្បុរសអីបានលេបចឹងនោះ
ទេ។

ក៖ ចាស

ខ៖
ហើយចៃពេលឈឺអីនុងក៏ចេះតែទៅធ្វើការទាំងឈឺហើយពេលនុងព្រោះអីខ្លាចគេយកទៅស
ម្លាប់ចោលដោយសារតែគេចោទថាជាខ្មាំង
គេឆាប់យកទៅសម្លាប់ខ្លាចហើយធ្វើតែចឹងដើម្បីអោយបានរស់នៅយូរ។
ចឹងមីស្រីលក្ខ័កូនខ្ញុំវាលឺចឹងទៅវាថា

កាលនៅជំនាន់របស់ម្ដាយឯងស្ដាប់ទៅភ័យខ្លាចណាស់នេះ
បើសិនជាខ្ញុំនៅក្នុងជំនាន់នុងវិញមិនដឹងថាខ្ញុំមានការភ័យខ្លាចយ៉ាណានោះទេ។

ក៖ ចាស

ខ៖ វាបានថាចឹង!

ក៖
ចឹងមុនហ្នឹងបញ្ចប់ខ្ញុំសូមអរគុណដល់ថៃដែលបានចំណាយពេលវេលាដ៏មានតំលៃដើម្បីអោយ
ដឹងពីជីវៈប្រវត្តិរបស់ថៃចឹងខ្ញុំសូមជូនពរដល់ថៃអោយមានសុខភាពល្អ
ទៅទីណាមកណាបានជួបតែសេចក្ដីសុខចំរើនណាថៃ។

ខ៖ អឺ!ថៃក៏សូមជូនពរដល់ប្អូនដែរអោយប្រកបដោយសេចក្ដីសុខ។

ក៖ ចាស!ថៃសូមអរគុណច្រើន។

ខ៖ អឺបានសុខទាំងអស់គ្នា!

ក៖ មុនហ្នឹងបញ្ចប់ប្អូនសូមថតរូបថៃ១ប៉ុស
ដើម្បីទុកជាអនុស្សាវរីយ៍និងបញ្ចូលនៅក្នុងគេហៈទំព័ររបស់សកលវិទ្យាល័យព្រមទាំងរូបថៃ
សម្លេងរបស់ថៃដែរបើសិនជាថៃចង់ស្ដាប់ថៃអាចចូលទៅក្នុងគេហៈទំព័រCambodian Oral
History.byu.edu

ខ៖ មិនអីនោះទេ។